# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 528

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការសាងសង់មជ្ឈមណ្ឌល ជំរុញ អភិវឌ្ឍ ន៍ សហគ្រាស ធុន តូចនិងមធ្យម

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/20 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/22 |
| ៣. ចំណាយគម្រោងសរុប | $1,419,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| RESPONSIBLE UNIT | General Department of Small & Medium Enterprises and Handicraft |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ស្វែងរកម្ចាស់ជំនួយ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ក្នុងគោលដៅអនុវត្តឱ្យមានប្រសិទ្ធិភាពនូវ គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា លើទិសដៅលើកស្ទួយឧស្សាហកម្ម និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម មជ្ឈមណ្ឌលជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម(SMEDPC) គ្រោងបង្កើតឡើង ដើម្បីជំរុញទំនើបកម្មសហគ្រាសធុនតូច និងមធ្យម ការបង្កើតការទាក់ទាញនិងជំរុញទឹកចិត្តអ្នកវិនិយោគក្នុងវិស័យ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មក្នុងតំបន់ដើម្បីអភិវឌ្ឍឈានឡើងក្នុងខ្សែច្រវាក់តម្លៃសកល ដូចខាងក្រោម៖

-ជួយសម្រួលដល់ការផ្ទេរបច្ចេកវិទ្យាជូនសហគ្រាសធុនតូច និងមធ្យម តាមរយៈការបង្កើតកម្មវិធីបណ្តុះបណ្តាលសហគ្រិនភាព ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មី(best Practice) ការសម្របសម្រួលឱ្យបានចូលរួមទស្សនកិច្ចសិក្សាផ្សេងៗក្នុង និងក្រៅប្រទេស

-ជំរុញពង្រឹងមូលដ្ឋានគ្រឹះ សមត្ថភាព និងសហគ្រិនភាពរបស់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ឱ្យមានលទ្ធភាពតភ្ជាប់បណ្តាញជាមួយសហគ្រាសធំៗ ជាមួយកម្រងចង្កោមសហគ្រាសដើម្បីបង្កើនផលិតភាព សមត្ថភាពច្នៃប្រឌិតនវានុវត្តន៍ និងឯកទេសកម្មការងារខ្ពស់ ព្រមទាំងជំរុញបង្កើតចង្កោមប្រព័ន្ធក្នុងខ្សែច្រវាក់ផលិតកម្ម និងការលើកកម្ពស់បច្ចេកទេស

-ជាយន្តការព័ត៌មាន និងជាមជ្ឈមណ្ឌលប្រឹក្សាយោបល់លើផ្នែកធុរកិច្ចសហគ្រាសធុនតូច និងមធ្យម ដើម្បីសម្រួលលទ្ធភាពទទួលបានព័ត៌មានទីផ្សារ ព័ត៌មានបច្ចេកវិទ្យា ព័ត៌មានវិនិយោគ និងជាយន្តការជួយដោះស្រាយបញ្ហាធុរកិច្ច

-ជួយសម្របសម្រួល និងអនុវត្តមូលនិធិសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ (R&D) របស់រដ្ឋាភិបាល ដើម្បីជំរុញយន្តការគាំទ្រ និងបណ្តុះបណ្តាលអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផលនិងវត្ថុធាតុដើមក្នុងស្រុក ការលើកកំពស់គុណភាព ការជំរុញទំនើបកម្មខ្សែច្រវាក់តម្លៃផលិតកម្មសំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិសាសន និងមានសក្តានុពលនាំចេញ

-ជាយន្តការជួយបង្កើនចំនួន និងជំរុញវិស្វករជំនាញ ឱ្យក្លាយជាសហគ្រិនជាស្ត្រី សហគ្រិនវ័យក្មេង និងកាត់បន្ថយចំនួនអត្រាអត់ការងារធ្វើ ចំណាកស្រុករបស់កម្លាំងពលកម្ម កាត់បន្ថយសកម្មភាពអសកម្មក្នុងសេដ្ឋកិច្ចជាតិ និងបង្កើនចំណូលជូនប្រជាពលរដ្ឋ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម — Industry and Support Services

Industry and Support Services

Industry and Support Services

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

រាជធានីភ្នំពេញ,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

មជ្ឈមណ្ឌលជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម(SMEDPC) ត្រូវបានគ្រោងបង្កើតឡើង ជាមជ្ឈមណ្ឌលស្ថិតក្រោមនាយកដ្ឋានផែនការ និងជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដោយបំពេញការងារជំនួសមុខឱ្យនាយកដ្ឋានលើទួនាទីដូចខាងក្រោម៖
-ជាមជ្ឈមណ្ឌល ប្រឹក្សាយោបល់លើផ្នែកធុរកិច្ចសហគ្រាសធុនតូច និងមធ្យម និងផ្តល់ព័ត៌មានទីផ្សារ ព័ត៌មានបច្ចេកវិទ្យា ព័ត៌មានវិនិយោគ
-ជាមជ្ឈមណ្ឌល សម្របសម្រួលព័ត៌មាន និងបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញនិងសហគ្រិនភាព ការប្រគួតប្រជែងនិងទីផ្សារ ការកែច្នៃនិងអភិវឌ្ឍផលិតកម្ម
-ជាមជ្ឈមណ្ឌល រៀបចំ និងសម្របសម្រួលជំរុញកម្មវិធីប្រលងប្រណាំងបច្ចេកវិទ្យា វិស្វករមានទេពកោសល្យ អ្នកមានគំនិតផ្តួចផ្តើមបង្កើតធុរកិច្ចថ្មីៗ ដើម្បីជំរុញកំណើនសហគ្រាសវ័យក្មេង សហគ្រាសស្ត្រី និងនវានុវត្តវិស្វកម្មការងារ
-ជាមជ្ឈមណ្ឌល សិក្សាស្រាវជ្រាវ និងអភិវឌ្ឍផលិតផល ជំរុញគុណភាព ជំរុញបច្ចេកទេសកែច្នៃ និងគ្រប់គ្រងដោះស្រាយរបាំងបច្ចេកវិទ្យាផ្សេងៗ គួបផ្សំជាមួយនវានុវត្តន៍បច្ចេកវិទ្យាថ្មី និងបច្ចេកវិទ្យាបៃតង។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

1/.ការបណ្តុះបណ្តាលក្រៅប្រព័ន្ធ និងភាពជាដៃគូរ៖
-ជំរុញភាពជាដៃគូររវាងរបស់មជ្ឈមណ្ឌល ទៅនឹងមហាវិទ្យាល័យ គ្រឹះស្ថាន វិទ្យាស្ថាន អង្គការជាតិ និងអន្តរជាត ក្នុងការអភិវឌ្ឍន៍ និងអប់រំសហគ្រិន ដែលជាយន្តការមានប្រសិទ្ធិភាពដើម្បីអភិវឌ្ឍជំនាញ ការផ្ទេរបច្ចេកវិទ្យា និងការតភ្ជាប់បណ្តាញផលិតកម្មទៅក្នុងខ្សែរច្រវ៉ាក់តំលៃសកល តាមរយៈការរៀបចំ និងផ្តល់ព័ត៌មានកម្មវិធីបណ្តុះបណ្តាល និងការគាំទ្រផ្សេងៗ
-គំនិតផ្តួតផ្តើម និងលើកទឹកចិត្តឱ្យចែករំលែកព័ត៌មាន និងផ្ទេរបច្ចេកវិទ្យារបស់សហគ្រាសធុនធំ និងសាជីវកម្មចំរុះជាតិសាសន៍ ជាយុទ្ធសាស្ត្រមានប្រយោជន៍ក្នុងការ អភិវឌ្ឍនសហគ្រាសក្នុងស្រុកឱ្យចូលរួមបំពេញតម្រូវការផ្គត់ផ្គង់ និងកាត់បន្ថយថ្លៃដើមជូនសហគ្រាសធុនធំ ព្រមទាំងអាចតភ្ជាប់បណ្តាញទំនាក់ទំនង និងប្រឹក្សាយោបល់ក្រោមគម្រោងឧបត្ថមរបស់សហគ្រាសធុនធំ
2/.ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញសហគ្រិនភាពដែលមានប្រសិទ្ធិភាព៖
-ជំរុញជំនាញគ្រប់គ្រងសហគ្រាស ដែលផ្តល់ឱកាសឱ្យសហគ្រិនអាចចាប់ផ្តើមបង្កើត និងដំណើរការអាជីវកម្ម រួមមានមុខវិជ្ជា ការវិភាគលើគុណសម្បត្តិក្នុងការប្រគួតប្រជែង ការសិក្សាស្រាវជ្រាវទីផ្សារ ការអភិវឌ្ឍផែនការអាជីវកម្ម ទីផ្សារ ការគ្រប់គ្រងការលក់ និងការគ្រប់គ្រងធុនជានមនុស្ស
-ជំរុញជំនាញអភិវឌ្ឍភាពជឿរជាក់លើខ្លួនឯង ដើម្បីឱ្យសហគ្រិនយល់ដឹងអំពីតួនាទីជានិយោជក និយោជិក និងអាចដឹងពីភាពមិនប្រកដប្រជាក្នុងដំណោះស្រាយរបស់ខ្លួន រួមមានមុខវិជ្ជា ការងារក្រុម ភាពជឿរជាក់លើខ្លួនឯង ការសម្រេចចិត្តបង្កើត ការគណនានិងគ្រប់គ្រងហានីភ័យ វិធីសាស្ត្រដោះស្រាយបញ្ហា និងការបង្កើតការងារ
-ជំរុញជំនាញប្រតិបត្តិការ ដើម្បីជំរុញមូលដ្ឋានគ្រឹះក្នុងការប្រតិបត្តិឱ្យមានប្រសិទ្ធិភាព និងអាចគ្រប់គ្រងបរិស្ថានធុរកិច្ច និងគម្រោងថវិការបស់ខ្លួន រួមមានមុខវិជ្ជា គណនេយ្យ ការគ្រប់គ្រងគម្រោងថវិកា ការគ្រប់គ្រងគម្រោង ប្រព័ន្ធព័ត៌មានវិទ្យា វិស្វកម្មឧស្សាហកម្ម វិស្វកម្មបច្ចេកវិទ្យា និងច្បាប់ពាណិជកម្ម ច្បាប់ឧស្សាហកម្ម ច្បាប់តស្តង់ដារ និងបទដ្ឋានគត្តិយុតពាក់ព័ន្ធផ្សេង
3/.ការបណ្តុះបណ្តាលគ្រូបង្គោល៖
-ជំរុញគរុសិស្សគ្រូបង្រៀន ជាគន្លឹះក្នុងការបង្កើតមូលដ្ឋាន និងអភិវឌ្ឍភាពរីកចំរើន និងការយល់ដឹងរបស់សហគ្រាស។ លើសពីការបណ្តុះបណ្តាលតាមប្រព័ន្ធ ការលើកទឹកចិត្ត និងការផ្តល់ពានរង្វាន់ចំពោះប្រធានវិទ្យាស្ថាន មជ្ឈមណ្ឌលអប់រំ និងសហគ្រាសជោគជ័យអាជីវកម្ម អាចជាគំនិតផ្តួតផ្តើមថ្មលបណ្តុះបណ្តាលគ្រូបង្រៀនថ្មីដែលមានគុណសម្បត្តិ និងសក្តានុពលបង្ហឹកដោយហេតុថា ពួកគេមានភាពទាក់ទាញពីអ្នកដទៃឱ្យសន្ទះចូលរួមសិក្សា ចែករំលែកបទពិសោធ ដើម្បីប្តេជ្ញចិត្តអនុវត្តតាមកម្មវិធីជោគជ័យ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ
4/.ការផ្តល់ព័ត៌មាន និងដោះស្រាយបញ្ហាធុរកិច្ច៖
-ជំរុញបណ្តាញទំនាក់ទំនងយ៉ាងទូលាយ និងឆាប់រហ័ស(Digital network) និងផ្តល់ព័ត៌មានជុំវិញបញ្ហាធ្វើអាជីវកម្ម ការបង្កើតអាជីវកម្ម និងតម្រូវការទីផ្សារ
-ជំរុញរៀបចំចងក្រង និងផ្សព្វផ្សាយយ៉ាងទូលាយបែបបទពាក់ព័ន្ធ គំរូអាជីវកម្ម ព័ត៌មានទីផ្សារ ព័ត៌មានអ្នកផ្គត់ផ្គង់ ព័ត៌មានបច្ចេកកវិទ្យាផ្សេងៗ

-ដើរតួជាឈ្នួញកណ្តាលដើម្បីរៀបចំកម្មវិធីជំនួបទំនាក់ទំនងពាណិជ្ជកម្មរវាងសហគ្រាស និងសហគ្រាស ឬរវាងសហគ្រាស និងអ្នកផ្គត់ផ្គង់ ឬរវាងសហគ្រាស និងភ្នាក់ងារលក់បន្តក្នុង និងក្រៅប្រទេស

5/.ការជំរុញសហគ្រាសជាស្ត្រី និងសហគ្រាសវ័យក្មេង៖

-ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់លើកស្ទួយសេដ្ឋកិច្ចជាតិ ពិសេសក្នុងវិស័យសហគ្រាសធុនតូច (miro-sme) ដូច្នេះវាទាមទារឱ្យមានយន្តការជំរុញគាំទ្របច្ចេកទេស និងសហគ្រិនភាពរបស់ស្ត្រីដើម្បីជាដោះស្រាយលើបញ្ហាកង្វល់យេនឌ័រ និងការធានាលទ្ធភាពស្ត្រីទទួលបានគោលនយោបាយលើកទឹកចិត្ត

-សហគ្រាសវ័យក្មេង ជាក្រុមថាមពលស្នូលនៃការអភិវឌ្ឍសហគ្រាសប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ដែលត្រូវមានយន្តការជំរុញជំនាញផ្សេងៗដូចជា ជំនាញគ្រប់គ្រង វិស្វកម្មនិងផលិតកម្ម ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រងធនធានមនុស្ស

6/.ការជំរុញសហគ្រាសជនបទ និងសហគ្រាសសហគមន៍៖

-យន្តការជំរុញសហគ្រាសតាមទីជនបទ ជាផ្នែកមួយយ៉ាងសំខាន់ដើម្បីកាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍ ហើយការចងក្រងសហគ្រាសតាមទីជនបទ ជួយឱ្យពួកគេបង្កើន ចំណេះដឹង ចែករំលែកបទពិសោធន៍ និងផ្តល់ឱកាសការងារថ្មីជូនប្រជាជន។ ការលើកស្ទួយអាជីវកម្ម តាមតំបន់ដែលមានអត្រាភាពក្រីក្រខ្ពស់ រួមចំណែកលើកស្ទួយកំណើន និងពង្រឹងនិរន្តរភាពដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

-សហគ្រាសសហគមន៍ ជាសមាសធាតុប្រកបដោយភាពច្នៃប្រឌិតរួមបញ្ចូលក្នុងផលិតផលមូលដ្ឋានតាមសហគមន៍តូចៗ ហើយមានសក្តានុពលបំពេញតម្រូវការ ទីផ្សារផលិតផល ទេសចរណ៍ និងប្រពៃណី។ ការអភិវឌ្ឍដើម្បីអភិរក្សសហគ្រាសសហគមន៍ប្រភេទនេះ មានគោលបំណងដោះស្រាយភាពអសកម្ម និងការថយចុះសកម្មភាពសេដ្ឋកិច្ចតាមសហគមន៍ដាច់ស្រយាល និងទិសដៅទេសចរណ៍

7/.ការបង្កើតពានរង្វាន់ប្រគួតប្រជែងបច្ចេកទេស៖

-កម្មវិធីពានរង្វាន់បច្ចេកវិទ្យា ជាយន្តការជំរុញឱកាសកម្មករជំនាញ សិស្សនិស្សិតឱ្យធ្វើការអភិវឌ្ឍចំណេះ និងជំនាញរបស់ខ្លួនដើម្បីស្វែងរកឱកាសការងារ និងអាជីវកម្មថ្មី

-កម្មវិធីពានរង្វាន់សហគ្រាសជោគជ័យ ជាយន្តការបណ្តុះបណ្តាល និងជំរុញឱ្យសហគ្រាសផ្សេងកែលំអ និងអភិវឌ្ឍខ្លួន ពង្រីកសមត្ថភាពប្រកួតប្រជែង និងចាប់យកសក្តានុពលថ្មីៗ

-កម្មវិធីពានរង្វាន់សហគ្រាសជាស្ត្រី ជាយន្តការដោះស្រាយបញ្ហាយេនឌ័រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសជំរុញកំណើនសហគ្រាសធុនតូច ដែល មានតម្រូវការបច្ចេកទេសទាប

8/.ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ

-ជួយដោះស្រាយបញ្ហាកង្វះខាតផ្នែកបច្ចេកទេស ការកែលំអខ្សែរច្រវ៉ាក់ផលិតកម្ម ការជំរុញនវានុវត្តផលិតកម្មថ្មី

-ជំរុញលើកកម្ពស់ការកែច្នៃកសិផល វត្ថុធាតុដើមក្នុងស្រុក និងការកាត់បន្ថយបន្ទុកចំណាយវត្ថុធាតុដើមនាំចូល

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងបង្កើតមជ្ឈមណ្ឌលជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម(SMEDPC)
បានបង្កើតឡើងដើម្បីបំពេញតួនាទីជាក់លាក់ជំនួសឱ្យនាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញ ការអប់រំបច្ចេកទេស ការដោះស្រាយបញ្ហាកង្វះព័ត៌មាន
និងការសិក្សាស្រាវជ្រាវអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។
ម្យ៉ាងវិញទៀត ក្នុងទិសដៅសម្រេចឱ្យបានតាមអភិក្រមនៃការអនុវត្តក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥
-២០២៥ ដែលរាជរដ្ឋាភិបាលបាននិងតម្រង់ទិសលើការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់ៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម
និងសហគ្រាសធុនតូច និងមធ្យម ពិសេសពាក់ព័ន្ធនិងការបណ្តុះបណ្តាលជំនាញ ការអប់រំបច្ចេកទេស ការជំរុញនវានុវត្តបច្ចេកវិទ្យា
និងការផ្គត់ផ្គង់ធាតុដើមនោះ មជ្ឈមណ្ឌលនេះ និងជួយបំពេញយន្តការរបស់រាជរដ្ឋាភិបាលក្នុងការងារដូចជា៖
-រៀបចំយន្តការសម្របសម្រួលរវាងសកលវិទ្យាល័យ វិទ្យាស្ថាន និងគ្រឹះស្ថានឯកជន
ដើម្បីកសាងវគ្គកម្មវិធីបណ្តុះបណ្តាលជំនាញស្របតាមតម្រូវការស្ថានភាពបច្ចុប្បន្ន
-រៀបចំយន្តាគកម្មវិធីជាក់លាក់សម្រាប់ជំរុញអភិវឌ្ឍ ដោយផ្តោតលើកិច្ចសហប្រតិបត្តិការ រវាងសាកលវិទ្យាល័យ
ស្ថាប័នស្រាវជ្រាវផ្សេងៗក្នុង និងក្រៅប្រទេស ដើម្បីសិក្សា វិភាគ និងផ្តល់ប្រឹក្សាយោបល់អំពីការអភិវឌ្ឍផលិតផល
ការរៀបចំខ្សែច្រវ៉ាក់ផលិតកម្ម ការអភិវឌ្ឍបច្ចេកទេសថ្មី និងការជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យា
-រួមចំណែកសិក្សាស្រាវជ្រាវ បង្កើនផលិតភាព គុណភាព និងគុណប្រយោជន៍វត្ថុធាតុដើមក្នុងស្រុក
ដើម្បីជំរុញនិរន្តភាពផ្គត់ផ្គង់វត្ថុធាតុដើមថោក និងមានគុណភាព ឈានដល់ការកាត់បន្ថយថ្លៃផលិតកម្ម គុណសម្បត្តិប្រកួតប្រជែង
និងការនាំចេញ
-ជាយន្តការចែករំលែកព័ត៌មានបានឆាប់រហ័សអំពីតម្រូវការទីផ្សារ ព័ត៌មានផ្លាស់ប្តូរបច្ចេកវិទ្យា នវានុវត្តន៍បច្ចេកវិទ្យាថ្មី
និងដោះស្រាយបញ្ហាធុរកិច្ច
-ជាយន្តការអនុវត្តផ្ទាល់លើកម្មវិធីគាំទ្រ និងលើកទឹកចិត្តតាមរយៈពានរង្វាន់សហគ្រាសវ័យក្មេង សហគ្រាសជាស្ត្រី សហគ្រាសជោគជ័យ
និងកម្មវិធីផ្សព្វផ្សាយផលិតផល របស់សហគ្រាស។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ក្រោយគម្រោងត្រូវបានអនុវត្ត យើងនឹងទទួលបានផលប្រយោជន៍ដូចជា៖
-ចំពោះក្រសួង៖ បានបង្កើតមជ្ឈមណ្ឌល
ដែលមានភារកិច្ចជាក់លាក់ដើម្បីជួយបង្រួមកម្មវិធីយុទ្ធសាស្រ្តក្រសួងឱ្យមានភាពច្បាស់លាស់ត្រឹមត្រូវជំរុញអនុវត្តតាមអភិក្រម
នៃការអនុវត្តក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២៥ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម
និងសហគ្រាសធុនតូច និងមធ្យម ពិសេសពាក់ព័ន្ធនិងការបណ្តុះបណ្តាលជំនាញ ការអប់រំបច្ចេកទេស
ការជំរុញនវានុវត្តបច្ចេកវិទ្យានិងការផ្គត់ផ្គង់ជាតុដើម។ ក្នុងន័យនេះ មជ្ឈមណ្ឌលនិងមានកម្មវិធីបណ្តុះបណ្តាល កម្មវិធីពានរង្វាន់
កិច្ចសហប្រតិបត្តិការ កិច្ចការស្រាវជ្រាវ ការផ្តល់ព័ត៌មានដែលត្រឹមត្រូវឆ្លើយតបបានលើតម្រូវការ
និងដោះស្រាយបញ្ហាធុរកិច្ចជូនសហគ្រាសធុនតូច និងមធ្យមបានទាន់ពេលវេលា
-ចំពោះសហគ្រាសធុនតូច និងមធ្យម៖ ទទួលបានមជ្ឈមណ្ឌលព័ត៌មាន បណ្តុះបណ្តាល
និងអភិវឌ្ឍជាយន្តការជួយដោះស្រាយបញ្ហាកង្វះខាតនិងរបាំងផ្នែកបច្ចេកវិទ្យា ការកែលំអខ្សែរច្រវាក់ផលិតកម្ម
ការលើកកម្ពស់គុណភាព ការជំរុញសមត្ថភាពប្រកួតប្រជែង និងការតភ្ជាប់ខ្សែរច្រវាក់តម្លៃទៅនឹងខ្សែចង្វាក់តម្លៃសាកល ព្រមទាំង
សហគ្រាសជាស្ត្រី និងសហគ្រាសវ័យក្មេង ក៏ត្រូវបានពង្រឹងសមត្ថភាពដើម្បីដោះស្រាយបញ្ហាយេនឌ័រ
ការជំរុញវិស្វកម្មមានការច្នៃប្រឌិតខ្ពស់របស់កម្មករជំនាញ និងឱកាសអជីវកម្មថ្មីនៃយុវជនវ័យក្មេង។
-ចំពោះសេដ្ឋកិច្ចជាតិ ៖ រួមចំណែកបន្តកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយគម្លាតអភិវឌ្ឍនិងភាពក្រីក្រ ជំរុញកំណើនវិនិយោគ
និងបង្កើតការងារជូនប្រជាជន។ លទ្ធផលរំពឹងទុកនៃគម្រោង គឺចំនួន និងកំណើនរបស់សហគ្រាសធុនតូច និងមធ្យម ត្រូវបានកើនឡើង
និងធ្វើទំនើបកម្មដើម្បីតភ្ជាប់ទៅនឹងខ្សែរច្រវាក់តម្លៃសកល។ ក្នុងន័យនេះ
គម្លាតអភិវឌ្ឍតាមតំបន់ជនបទដែលមានអត្រាអ្នកក្រីក្រខ្ពស់ត្រូវបានកាត់បន្ថយ បញ្ហាយេនឌ័រត្រូវបានដោះស្រាយ
សហគ្រាសមានសក្តានុពលច្នៃប្រឌិតខ្ពស់ត្រូវបានគាំទ្រ និងបង្កើនចំណូលដល់សេដ្ឋកិច្ចជាតិ
តាមរយៈការរីកចំណើនរបស់សហគ្រាសសហគមន៍មូលដ្ឋាន
ការចងចង្កោមសហគ្រាសជនបទដែលមានសក្តានុពលទេសចរណ៍និងប្រពៃណី
ការបង្កើតកម្មវិធីពានរង្វាន់ប្រកួតប្រជែងសហគ្រាស្រ្តីនិងសហគ្រាសវ័យក្មេង កម្មវិធីបណ្តុះបណ្តាលចំទិសដៅ
ការផ្តល់ព័ត៌មានទីផ្សារនិងបច្ចេកទេស ការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍផលិតកម្ម
ការជំរុញនិរន្តភាពនៃការផ្គត់ផ្គង់វត្ថុធាតុដើមក្នុងស្រុកមានតម្លៃថោក ការលើកកំពស់គុណភាពនិងសមត្ថភាពប្រកួតប្រជែង
និងការតភ្ជាប់បណ្តាញខ្សែរច្រវាក់តម្លៃសហគ្រាសទៅនឹងខ្សែរចង្វាក់តម្លៃសកល។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ?  គ្មាន

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

មជ្ឈមណ្ឌលជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម មានអត្ថប្រយោជន៍ក្នុងការអប់រំទូទៅដល់សហគ្រាសក្នុងព្រះរាជាណាចក្រកម្ពុជា
ឱ្យចូលរួមធ្វើសមាហរណកម្មគំរូ តាមរយៈការទទួលបាននូវព័ត៌ថ្មីៗពាក់ព័ន្ធ ការសហការកែលំអការរៀបចំនិងខ្សែរច្រវាក់ផលិតកម្ម
ការបង្កើនផលិតភាព និងការចូលរួមទទួលការបណ្តុះបណ្តាលដើម្បីបង្កើតចំណេះដឹង និងគំនិតច្នៃប្រឌិតថ្មីៗ។
វប្បធម៌សហគ្រាសនៃសមាហរណកម្មគំរូនឹងធ្វើការកែលំអបរិស្ថានធុរកិច្ចកម្ពុជា
ដោយផ្តល់ឱកាសឱ្យសហគ្រិនយល់ដឹងអំពីភារកិច្ចនិងការគ្រប់គ្រងសហគ្រាសរបស់ខ្លួន
ឱកាសអនុវត្តគុណសម្បត្តិសហគ្រិនក្នុងការជំរុញបណ្តុះបណ្តាលបច្ចេកទេសនិងផ្ទេរបច្ចេកវិទ្យា
ឱកាសយល់ដឹងអំពីភាពជោគជ័យរបស់សហគ្រិនឈានមុខ និងផ្តល់លទ្ធភាពដល់សហគ្រាសអាចប្រើប្រាស់ព័ត៌មានទទួល
ដើម្បីពង្រីកទំនាក់ទំនង និងអភិវឌ្ឍអាជីវកម្មប្រកបដោយភាពច្នៃប្រឌិតខ្ពស់រួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការងារ។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? គ្មាន

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
| --- | --- | --- |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្នុងគំនិតផ្តួចផ្តើមបង្កើតមជ្ឈមណ្ឌលជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ឱ្យកើតមាន និងបានអនុវត្តតាមវិធានការលើកកម្ពស់ និងជួយសម្រួលដល់កម្មវិធីជំរុញសហគ្រិនភាព បណ្តុះបណ្តាលជំនាញ អប់រំបច្ចេកទេស កែលំអផលិតកម្ម និងនវានុវត្តបច្ចេកវិទ្យាបានលុះត្រាតែគម្រោងនេះបានបំពេញតាមជំហានមួយចំនួនដូចជា៖

២៣. [illegible] ពប្រឈមនានា ដែល បណ្តាល

ឲ្យ[illegible]ច្ចុប្បន្នដែលសហគ្រិនទូទៅបានចាប់ផ្តើមដំណើរការ និងពង្រីកអាជីវកម្មរបស់ពួកគេ និងកំណត់បញ្ហាប្រឈមជាក់លាក់របស់ប្រទេស។ ដូច្នេះក្រោយជ្រើសរើសទីតាំង និងបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង មជ្ឈមណ្ឌលគួរៀបចំផែនការយុទ្ធសាស្ត្រអាទិភាពដើម្បីវាយតំលៃតួនាទីនៃភាពជាសហគ្រិនក្នុងគោលដៅអភិវឌ្ឍរួមប្រកបដោយចីរភាព។

-ទី២៖ កំណត់កម្មវិធីជំរុញសហគ្រិនភាពអាទិភាព និងគោលដៅជាក់លាក់លើប្រភេទសហគ្រាសសក្តានុពលអនុវត្ត ស្ថាប័នត្រូវសហប្រតិបត្តិការ ជំនាញត្រូវបណ្តុះបណ្តាល បច្ចេកវិទ្យាត្រូវកែលំអ និងកម្មវិធីផ្សេងៗទៀតដើម្បីជាជំនួយកំណត់អត្តសញ្ញាណគម្លាតរវាងកម្មវិធី និងផែនការយុទ្ធសាស្ត្រ។

-ទី៣៖ រៀបចំវិធានការសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាកង្វះខាតដែលបានកំណត់ និងពិនិត្យតាមដានផលប៉ះពាល់ដើម្បីធានានូវភាពពាក់ព័ន្ធ និងប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រ និងវិធានការនានា។

-ទី៤៖ ប្រើប្រាស់យន្តការសន្ទនាគ្នាក្នុងវិស័យសាធារណៈ និងវិស័យឯកជនដែលជាវិធីសាស្ត្រគន្លឹះជោគជ័យ និងមានប្រសិទ្ធភាពបំផុតដើម្បីកំណត់គោលបំណង និងទិសដៅដែលអាចវាស់វែងតាមបំរែបំរួលសូចនាករអនុវត្តសំខាន់ៗ។

គម្រោងពុំទាន់ដំណើរការនៅឡើយ។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

9

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 8.0 | 16.0 | 24.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 6.0 | 12.0 | 18.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 2.0 | 4.0 | 6.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 465.0 | 465.0 | 465.0 | 1,395.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 400.0 | 400.0 | 400.0 | 1,200.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 40.0 | 40.0 | 40.0 | 120.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 5.0 | 5.0 | 5.0 | 15.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 465.0 | 473.0 | 481.0 | 1,419.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 465.0 | 473.0 | 481.0 | 1,419.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: